លោកុ.៤៩:១៦-៥០:២៦

**ដាន់នឹងជំនុំជំរះពួកវា ទុកដូចជាពូជអំបូរអ៊ីស្រាអែល១ ដាន់នឹងធ្វើជាពស់នៅក្នុងផ្លូវ គឺជាពស់វែកនៅផ្លូវច្រកដែលចឹកកែងជើងសេះឱ្យអ្នកជំនិះធ្លាក់ផ្ងារក្រោយ ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានរង់ចាំសេចក្តីសង្គ្រោះរបស់ទ្រង់ (លោកុ.៤៩:១៦-១៨)។**

ដាន់ត្រូវការសេចក្តីសង្គ្រោះពីព្រះជាម្ចាស់យ៉ាងខ្លាំង ពីព្រោះដាន់និងពូជពង្សរបស់លោកតែងតែនាំគេឯងអោយបះបោរ។ យើងនឹងឃើញរឿងរបស់គាត់ពេលយើងទាំងអស់គ្នាសិក្សាព្រះបន្ទូលជាបន្តទៅទៀត។

**ឯកាឌ់នឹងមាន១ហ្វូងមកប្រជ្រៀតលើវា តែវានឹងដេញប្រកិតតាមកែងគេវិញ (លោកុ.៤៩:១៩)។**

គ្រួសារកាឌ់ក៏ជាគ្រួសារមួយ ដែលតាំងទីលំនៅ នៅផ្នែកខាងជើងនៃប្រទេសដែរ។

**ឯអេស៊ើរ អាហារវានឹងបានវិសេស ហើយវានឹងផ្គត់ផ្គង់របស់**

**យ៉ាងធ្លាញ់ថ្វាយស្តេច ណែបថាលី ជាក្តាន់ដែលគេលែង វានឹង ពោលពាក្យពីរោះស្តាប់(លោកុ.៤៩:២០-២១)។**

នៅក្នុងព្រះគម្ពីរទាំងមូល ហេតុការណ៍ទាំងឡាយដែលកើតឡើងមកនោះ សុទ្ធតែកើតឡើងចេញពីគ្រួសារណាមួយ របស់ពួកកូនចៅ អ៊ីស្រាអែលទាំងដប់ពីរ អំបូរនេះ។

**យ៉ូសែបជាមែកឈើមានផ្លែ ជាមែកឈើមានផ្លែដែលដុះ នៅជិត រន្ធទឹក ខ្នែងវានឹងវារពាក់លើកំផែង (លោកុ.៤៩:២២)។**

យ៉ូសែបបានចាកចេញពីទឹកដីកាណាន ហើយទៅរស់នៅក្នុងប្រទេសអេស៊ីព្ទ។ ប៉ុន្តែទោះបីលោកទៅនៅប្រទេសអេស៊ីព្ទក៏ដោយ ក៏លោកតែងតែធ្វើទីបន្ទាល់ពីព្រះជាម្ចាស់ជានិច្ច។ ក្រោយមកទៀតកូនទាំងពីររូបរបស់លោកយ៉ូសែប មួយឈ្មោះ អេប្រាអិម មួយទៀតឈ្មោះម៉ាន៉ាសេ បានត្រឡប់មកតាំងទីលំនៅឯទឹកដីសន្យាវិញ នៅក្នុងខេត្តសាម៉ារី។ ខេត្តនេះ នៅសម័យព្រះយេស៊ូវគេហៅថា ជាខេត្តរបស់សាសន៍ដ៏ទៃ។

**ពួកពលធ្នូបានធ្វើទុក្ខវាជាខ្លាំង ទាំងបាញ់ទាំងស្អប់វាផង តែធ្នូវា នៅតែខ្លាំងពូកែ ដៃវាក៏មានកំឡាំងដោយសារព្រះហស្តនៃព្រះដ៏**

> **មានព្រះចេស្តារបស់យ៉ាកុប ឯអ្នកគង្វាល គឺជាថ្មដារបស់អ៊ីស្រាអែល បានចេញពីនោះមក គឺដោយនូវព្រះនៃឪពុកឯង ដែលទ្រង់នឹងជួយឯង ហើយដោយនូវព្រះដ៏មានគ្រប់ទាំងព្រះចេស្តា ដែលទ្រង់នឹងប្រទានពរដល់ឯង ជាព្រះពរពីលើមេឃ ហើយជាព្រះពរពីទីជំរៅដែលនៅខាងក្រោម ទាំងផលរបស់ដោះ ហើយនឹងពោះផង (លោកុ.៤៩:២៣-២៥)។**

អំបូរអេប្រាអិម និងម៉ាន៉ាសេមានឥទ្ធិពលខ្លាំងណាស់ ដូច្នេះហើយបានជានៅគ្រាដែលនគរអ៊ីស្រាអែលត្រូវបំបែកគ្នាជាពីរនោះ អំបូរទាំងពីរនេះជាអ្នកនាំមុខក្នុងការបំបែកបំបាក់នោះ។

> **ពររបស់ឪពុកឯង នោះលើសជាងអស់ទាំងពររបស់ពួកឰយុកោអញ ជាពរធំដល់ព្រំចុងបង្អស់របស់ភ្នំដ៏នៅអស់កល្បជានិច្ច ហើយក៏នៅលើក្បាលយ៉ូសែប គឺនៅលើកំពូលក្បាលនៃអ្នកដែលបានញែកចេញពីពួកបងប្អូនវា (លោកុ.៤៩:២៦)។**

លោកយ៉ាកុបព្យាយាមដាស់តឿនដល់យ៉ូសែប ហើយនិងដល់ពូជអំបូរពីរទៀត ដែលកើតពីកូនលោក អោយបែរត្រឡប់មករកព្រះនៃអ៊ីស្រាអែល ដែលជាតួអង្គ អាទិករ និងជាតួអង្គព្រះប្រោសលោះ។ ហេតុអ្វី? ពីព្រោះពូជអំបូរទាំងពីរនេះ មាន អេប្រាអិមជាដើម ជាអ្នកនាំអ៊ីស្រាអែលអោយថ្វាយបង្គំរូបព្រះ។ យេរ៉ូបោមដែលដឹក នាំមនុស្សអោយថ្វាយបង្គំរូបគោនៅព្រំប្រទល់ប្រទេសអ៊ីស្រាអែល ជាពូជពង្សរបស់ អេប្រាអិម។ ដូច្នេះហើយ បានជានៅក្នុងបណ្តាំចុងក្រោយបង្អស់មុននឹងគាត់ស្លាប់ យ៉ាកុបបានអំពាវនាវហៅអោយពូជពង្សទាំងពីរនេះ បែរត្រឡប់មកព្រះអង្គវិញ គឺជា ព្រះនៃពួកព្ទយុកោ របស់លោក។

**បេន-យ៉ាមីន ជាឆ្កែព្រៃដែលហែកស៊ី នៅពេលព្រឹកវាខាំស៊ីរំពា ហើយដល់ពេលល្ងាចវាចែករបឹប (លោកុ.៤៩:២៧)។**

បទទំនាយនេះមានលក្ខណៈចម្លែកណាស់ សម្រាប់បេន-យ៉ាមីន។ បេន-យ៉ាមីន ហើយនិងយូដាច្រើននៅជាមួយគ្នាជានិច្ចជាកាល ពិសេសពេលដែលនគរបាន បែកបាក់គ្នានោះ មានតែគ្រួសារនេះទេ ដែលស្ម័គ្រចិត្តទៅនៅជាមួយនឹងគ្រួសារ យូដា។ គ្រួសារបេន-យ៉ាមីនបានរស់នៅជានិច្ចជាកាលជាមួយនឹងគ្រួសារយូដា ដែល ក្រោយមកទៀតក្សត្រដាវីឌ បានប្រសូតចេញមក។

## បណ្តាំចុងក្រោយ និងមរណៈភាពរបស់យ៉ាកុប

**គាត់ក៏ផ្តាំថា អញហៀបនឹងបានប្រមូលទៅមូលនឹងញាតិអញ ហើយ ចូរកប់អញនៅជាមួយនឹងជីតាជីដូនរបស់អញ ក្នុងរអាងដែល នៅឯចំការរបស់អេប្រុនជាសាសន៍ហេតទៅ (លោកុ.៤៩:២៩)។**

លោកយ៉ាកុបសម្លឹងឃើញសេចក្តីស្លាប់របស់លោក ថាមិនមែនជាទីបញ្ចប់នៃជីវិតទេ។ លោកមានសង្ឃឹមថា លោកនឹងត្រូវប្រមូលទៅរស់នៅ ជាមួយនឹងពួកឰយុកោរបស់លោកទាំងអស់។ លោកចង់អោយគេយកសពលោកទៅបញ្ចុះនៅក្នុងផ្នូរដែលលោកអ័ប្រាហាំបានទិញ សម្រាប់ធ្វើជាទីបញ្ចុះសព។ លោកចង់អោយសពរបស់លោកបានបញ្ចុះនៅក្នុងទឹកដីសន្យា ពីព្រោះលោកជឿថាពេលដែលលោករស់ពីស្លាប់ឡើងវិញ លោកនឹងរស់នៅជាមួយពួកឰយុកោរបស់លោក នៅក្នុងទឹកដីនោះជានិរន្តន៍តរៀងរហូតដល់អស់កល្បជានិច្ច។

**គឺក្នុងរអាងដែលនៅចំការម៉ាក់ពេឡា ទល់មុខនឹងម៉ាមរេនៅស្រុកកាណាន ដែលអ័ប្រាហាំបានទិញ ជាមួយនឹងចំការនោះ ពីអេប្រុនសាសន៍ហេត ទុកសំរាប់ជាទីកប់ខ្មោច (លោកុ.៤៩:៣០)។**

យ៉ាកុបស្គាល់សាវតាររបស់គ្រួសារលោកច្បាស់លាស់ណាស់។ ខ្ញុំយល់ថាលោកប្រហែលជាមិនបានសរសេរបញ្ជីរបស់គ្រួសារលោកទុកនៅជាមុនទេ ប៉ុន្តែ

លោកចាំច្បាស់នៅក្នុងចិត្តរបស់លោក នូវពង្សាវតាលំអិតរបស់គ្រួសារលោកផ្ទាល់តែម្តង។

**គឺនៅទីនោះដែលគេបានកប់សពអ័ប្រាហាំ នឹងសារ៉ាជាប្រពន្ធគាត់ ហើយនៅទីនោះ គេបានកប់សពអ៊ីសាកនឹងរេបិកាប្រពន្ធគាត់ ហើយគឺនៅទីនោះ ដែលអញបានកប់សពលេអាដែរ (លោកុ.៤៩:៣១)។**

លោកចង់អោយគេបញ្ចុះសពលោកនៅទីនោះ មិនមែនគ្រាន់តែដោយសារជាកន្លែងដែលសពប្រពន្ធលោកឈ្មោះលេអាត្រូវបញ្ចុះនៅទីនោះដែរនោះទេ។ ចំណែកឯសពរបស់នាងរ៉ាជែលត្រូវបញ្ចុះនៅឯបេថ្លេហិមវិញ។ ប៉ុន្តែលោកចង់អោយគេ យកសពលោកទៅបញ្ចុះនៅទីនោះ ពីព្រោះលោកជឿថា នៅពេលដែលមានការរស់ឡើងវិញ លោកស្ថិតនៅក្នុងទឹកដីសន្យាដែលព្រះជាម្ចាស់ថា នឹងប្រទានមកអោយនគរអ៊ីស្រាអែល។

**ឯចំការនឹងរអាងនោះបានទិញពីពួកកូនថោហេតហើយ កាលយ៉ាកុបបានផ្តាំដល់ពួកកូនរួចស្រេចហើយ នោះគាត់លើកជើងដាក់លើគ្រែវិញ ហើយក៏ផុតដង្ហើមទៅ បានប្រមូលទៅមូលនឹងញាតិរបស់គាត់ (លោកុ.៤៩:៣២-៣៣)។**

មុននឹងលោកដកដង្ហើមចុងក្រោយបង្អស់ លោកយ៉ាកុបលើកជើងដាក់លើគ្រែវិញ ហើយក៏បង្ហើយដង្ហើមចុងក្រោយរបស់លោកទៅ។ យ៉ាកុបចាប់ផ្តើមជីវិតរបស់លោកជាមួយនឹងនិស្ស័យសាច់ឈាម។ លោកកើតមកចាប់កែងជើងបងជាប់ បានជាគេហៅថា "ជាអ្នកប្រជែង"។ លោករស់នៅតាមភាពដែលលោក យល់ឃើញថាត្រូវ។ លោកប្រមូលអ្វីៗតាមតែលោកអាចប្រមូលបាន។ លោកប្រើមធ្យោបាយផ្ទាល់ខ្លួនដើម្បីធ្វើអ្វីៗដែលលោកយល់ថាល្អក្នុងជីវិត។ កាលលោកនៅក្មេងនៅឡើយ លោកពឹងពាក់លើកម្លាំងខ្លួនលោក ហើយលោកមិនចាំបាច់ត្រូវការព្រះជាម្ចាស់ឡើយ។

ប៉ុន្តែមកដល់ពីអែល ព្រះជាម្ចាស់បានបំបាក់កលោក។ បន្ទាប់ពីពេលនោះមកជីវិតរបស់លោក ដើរនៅក្នុងភាពពិការជានិច្ច។ លោកដើរជើងបីដោយយកឈើច្រត់ធ្វើជាជើងបន្ថែមមួយទៀត។ លោកមិនអាចដើរខ្លួនឯងបានទេ។ មកទល់ពេលនេះលោកឈឺធ្ងន់ដោយរោគជរាពាធិ៍ បានជាពេលលោកហៀបនឹងស្លាប់ លោកឈរយកឈើច្រត់មកធ្វើជាជន្ទល់ទប់ខ្លួនលោក។ ទីបំផុត លោកលើកជើងដាក់លើគ្រែវិញ ហើយក៏ផុតដង្ហើមទៅ។ លោកសង្ឃឹមថា នៅថ្ងៃដែលព្រះអម្ចាស់ទ្រង់ធ្វើអោយលោករស់ពីស្លាប់ឡើងវិញ លោកនឹងស្នាក់នៅក្នុងទឹកដីសន្យា ដែលព្រះជាម្ចាស់បានប្រទានមកអោយលោក។ គម្ពីរមួយបានចែងពីលោកថា : "ពួកអ្នកទាំងនោះ បានស្លាប់ក្នុងសេចក្តីជំនឿ ឥតទទួលសេចក្តីដែលបានសន្យាទាំងប៉ុន្មានទេ តែគេបានឃើញពីចំងាយ ហើយក៏ទទួលគំនាប់ដែរ ទាំងយល់ព្រមថា ខ្លួនគេជាអ្នកដទៃ ដែលគ្រាន់តែសំណាក់នៅផែនដីប៉ុណ្ណោះ" (ហេព្រើរ១១:១៣)។

# ជំពូក ៥០

*ឆាកទសនា ពិធីបញ្ចុះសពយ៉ាកុបនៅស្រុកកាណាន*
*យ៉ូសែបរំងាប់ការភ័យខ្លាចរបស់ពួកបងប្អូន*
*មរណៈភាព និងពិធីបញ្ចុះសពយ៉ូសែបនៅអេស៊ីព្ទ*

ជំពូកនេះ បរិយាយអំពីការបញ្ចុះសពយ៉ាកុបនៅស្រុកកាណាន ព្រមទាំងមរណៈភាព និងការបញ្ចុះសពយ៉ូសែប នៅក្នុងទឹកដីអេស៊ីព្ទ។ ដូច្នេះនៅក្នុងព្រះគម្ពីរលោកុប្បត្តិ យើងមានបទពិសោធន៍សេចក្ដីសោកសៅ ដែលកើតឡើងមកពីសេចក្ដីស្លាប់។ នៅក្នុងព្រះគម្ពីរលោកុប្បត្តិទាំងមូល មានរៀបរាប់អំពីសេចក្ដីស្លាប់ជាច្រើនណាស់។ ព្រះជាម្ចាស់ព្រមានដល់អ័ដាំមថា "...នៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន"(លោកុ.២:១៧)។ សាវ័កប៉ូលសរសេរក្នុងពេលក្រោយមកទៀតថា "...នោះសេចក្ដីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ" (រ៉ូម៥:១២)។ កំណត់គម្ពីរលោកុប្បត្តិ មានហេតុការណ៍សម្ដែងអំពីអំពើបាប ហើយនិងហេតុការណ៍ជាក់ស្ដែងស្ដីអំពីសេចក្ដីស្លាប់។ ព្រះគម្ពីរនេះចាប់ផ្ដើមឡើង ឃើញព្រះបង្កើតមនុស្សលោក ក្នុងសួនច្បារអេដែន ហើយបញ្ចប់រឿងរបស់ខ្លួន នៅក្នុងក្ដារមឈូសនៅប្រទេសអេស៊ីព្ទ។ មិនតែប៉ុណ្ណោះព្រះគម្ពីរនេះ

រៀបរាប់អំពីមនុស្សបើកទ្វារស្វាគមន៍អំពើបាប អោយចូលរុករាននៅក្នុងសង្គមរបស់ខ្លួន ប៉ុន្តែខគម្ពីរនេះ បានកត់ត្រាហេតុការណ៍ ដែលព្រះជាម្ចាស់សម្រេចប្រទានអោយមនុស្សអាចមានសេចក្តីសង្ឃឹមនៅក្នុងជីវិតតទៅមុខទៀតផងដែរ។

## ពិធីបញ្ចុះសពយ៉ាកុបនៅស្រុកកាណាន

**យ៉ូសែបក៏ក្រាបផ្កាប់នៅលើមុខឪពុក ទាំងយំហើយថើបគាត់ (លោកុ.៥០:១)។**

យ៉ូសែបពិតជាមនុស្សលោកមែន បានជាលោកក៏ចេះកើតទុក្ខដូចអ្នកដទៃដែរ។ លោកយំដោយសារឪពុកលោកស្លាប់។

**រួចយ៉ូសែបបង្គាប់ដល់គ្រូពេទ្យ ជាអ្នកបំរើគាត់ឱ្យដាក់បារទសពឪពុក ពួកគ្រូពេទ្យក៏ដាក់បារទសពអ៊ីស្រាអែលទៅ (លោកុ.៥០:២)។**

សាសន៍អេស៊ីព្ទពូកែដាក់បារទសពទុកអោយបានយូរណាស់។ យើងតែងតែឮនិយាយរឿងដែលទាក់ទងជាមួយនឹងសាសន៍អេស៊ីព្ទ រក្សាសពរបស់អ្នកដែលគេ

ស្រឡាញ់នោះ អោយបានយូជាទីបំផុត។ វិធីដែលគេរក្សាសពអោយបានយូរនោះ សព្វថ្ងៃនេះ យើងនៅតែមិនដឹងអាថ៌កំបាំងរបស់គេនៅឡើយទេ។ យ៉ូសែបបានហៅពួកគ្រូពេទ្យ ដើម្បីដាក់បារទសពឪពុករបស់ខ្លួន។

**គេរៀបចំឱ្យគាត់ពេញ៤០ថ្ងៃ ដ្បិតគឺគំរប់ថ្ងៃទាំងនោះដែលធ្លាប់ដាក់បារទខ្មោចទាំងប៉ុន្មាន ហើយពួកសាសន៍អេស៊ីព្ទគេនាំគ្នាកាន់ទុក្ខអស់៧០ថ្ងៃ (លោកុ.៥០:៣)។**

គ្រាន់តែដាក់បារទសពនេះ គេប្រើពេលអស់សែសិបថ្ងៃ។ ខ្ញុំយល់ថា ដើម្បីធ្វើអោយសពនេះ ទុកបានយូរ គេត្រូវដាក់បារទលើសពម្តងបន្តិចៗ ដើម្បីអោយសពអាចនៅយូរបាន។ សូមលោកអ្នកកត់ចំណាំថា សាសន៍អេស៊ីព្ទ ក៏ចូលរួមកាន់មរណៈទុក្ខនេះដែរ។ ខ្ញុំយល់ថា ការកាន់ទុក្ខនេះ មិនមែនជាការកាន់ទុក្ខបន្លំនោះឡើយ។ សព្វថ្ងៃនេះ មនុស្សកាន់ទុក្ខសពគ្រាន់តែបន្លំៗដោយយកស្នូតមកចាក់តាមមីក្រូ អោយក្មេងៗខ្លាចព្រឺក្បាលតែប៉ុណ្ណោះ។ ទម្លាប់អាក្រក់បែបនេះគួរតែត្រូវធ្វើការផ្លាស់ប្តូរហើយ។ ប៉ុន្តែមនុស្សទាំងអស់ដែលកាន់ទុក្ខសពយ៉ាកុប គេកាន់ទុក្ខពិតប្រាកដមែន ពីព្រោះគេឃើញថា លោកពិតជាមនុស្សរបស់ព្រះ ដែលទៅរស់នៅទឹកដីអេស៊ីព្ទ ហើយម្យ៉ាងទៀតគេគោរពថា លោកត្រូវជាឪពុករបស់យ៉ូសែបផង។ យ៉ូសែបជាអ្នកមានគុណជួយសង្គ្រោះដល់មនុស្សលោកអោយរួចពីអត់បាយ។

**រួចកាលផុតវេលាដែលគេកាន់ទុក្ខហើយ នោះយ៉ូសែបក៏ផ្តាំដល់ពួកដំណាក់ផារ៉ោនថា ឥឡូវបើខ្ញុំប្រកបដោយគុណនៃអ្នករាល់គ្នា នោះសូមទូលដល់ផារ៉ោនថា ឪពុកយើងបានឱ្យយើងស្បថដោយថា មើលអញត្រូវស្លាប់ ចូរឯងកប់សពអញនៅក្នុងផ្នូររបស់អញ ដែលអញបានជីកសំរាប់អញនៅស្រុកកាណាន ដូច្នេះសូមទ្រង់អនុញ្ញាតឱ្យយើងបានឡើងទៅកប់ខ្មោច របស់ឪពុកយើងឥឡូវ រួចយើងនឹងវិលត្រឡប់មកវិញ នោះផារ៉ោនទ្រង់មានបន្ទូលថា ចូរឡើងទៅកប់សពឪពុកអ្នកចុះ តាមដែលគាត់បានឱ្យអ្នកស្បថនោះ យ៉ូសែបក៏ឡើងទៅកប់សពឪពុក ហើយពួកមហាតលិកផារ៉ោនទាំងអស់ នឹងពួកចាស់ទុំនៅដំណាក់ទ្រង់ព្រមទាំងពួកចាស់ទុំនៅស្រុកអេស៊ីព្ទទាំងប៉ុន្មាន ក៏ឡើងទៅជាមួយដែរ (លោកុ.៥០:៤-៧)។**

ខ្ញុំយល់ថា ការដង្ហែរសពរបស់លោកយ៉ាកុបនេះ មានប្រវែងផ្លូវវែងជាងគេឯង ដែលធ្លាប់មាននៅក្នុងសកលលោកទាំងមូល។ លោកទទួលមរណៈភាពនៅប្រទេសអេស៊ីព្ទ ប៉ុន្តែដង្ហែរមកបញ្ចុះនៅស្រុកកាណានដែលមានចម្ងាយផ្លូវរាប់សិបគីឡូម៉ែត្រ ឯណោះវិញ។

**ហើយពួកផ្ទះយ៉ូសែប ទាំងបងប្អូនគាត់នឹងពួកផ្ទះឪពុកគាត់ទាំងអស់ផង សល់នៅតែកូនក្មេងនឹងហ្វូងចៀម ហ្វូងគោរបស់គេប៉ុណ្ណោះ ដែលទុកឱ្យនៅស្រុកកូសែន (លោកុ.៥០:៨)។**

ក្នុងការដង្ហែរសពលោកយ៉ាកុបមកបញ្ចុះនេះ ក្មេងៗហើយនិងហ្វូងសត្វរបស់គេនៅឯអេស៊ីព្ទនោះទេ។ យើងមិនដឹងថា ការនេះប្រហែលជាស្តេចផារ៉ោនបានរៀបចំយ៉ាងដូច្នេះ ឬមួយក៏យ៉ាងណាឡើយ។ ស្តេចផារ៉ោន មិនចង់អោយយ៉ូសែបមករស់នៅទឹកដីកាណានវិញទេ ពីព្រោះលោកត្រូវការយ៉ូសែបយ៉ាងខ្លាំង នៅក្នុងដំណាក់កាលនេះ។

**ក៏មានរទេះ នឹងពួកជិះសេះដង្ហែជូនគាត់ទៅជាហ្វូងមនុស្ស ដ៏ច្រើនក្រៃលែង គេទៅដល់លានស្រូវរបស់អ័ថាត់ ដែលនៅខាងនាយទន្លេយ័រដាន់ នៅទីនោះ គេទួញទំនួញជាខ្លាំង ហើយយ៉ូសែប ក៏កាន់ទុក្ខនឹងឪពុកអស់៧ថ្ងៃ កាលពួកអ្នកស្រុកនោះគឺពួកសាសន៍កាណាន បានឃើញគេកាន់ទុក្ខនៅត្រង់លានស្រូវអ័ថាត់ដូច្នោះ នោះគេនិយាយថា នេះជាការកាន់ទុក្ខយ៉ាងខ្លាំងណាស់ របស់ពួកសាសន៍អេស៊ីព្ទ បានជាគេហៅទីនោះថាអេបិល-មីសរ៉ែម ដែលនៅខាងនាយទន្លេយ័រដាន់ ពួកកូនចៅយ៉ាកុប ក៏ធ្វើសំរេចដល់គាត់ដូចជាគាត់បានផ្តាំទុក គឺពួកកូនចៅ**

**បានដឹកសពគាត់ ទៅដល់ស្រុកកាណានហើយបញ្ចុះនៅក្នុងរអាងនាចំការម៉ាក់ពេឡា ខាងមុខម៉ាមរេ ដែលអ័ប្រាហាំបានទិញពីអេប្រុនជាសាសន៍ហេត ជាមួយនឹងចំការនោះ ទុកជាទីកប់ខ្មោចរបស់ផងគាត់ (លោកុ.៥០:៩-១៣)។**

លោកអ្នកប្រហែលឆ្ងល់ថា ហេតុអ្វីបានជាយ៉ាកុបមិនចង់អោយគេយកសពលោកទៅបញ្ចុះជាមួយនឹងប្រពន្ធ ដែលជាទីស្រឡាញ់របស់លោកឈ្មោះរ៉ាជែលនៅបេថ្លេហិម ដែលមានចម្ងាយប្រមាណសាមសិបប្រាំមួយគីឡូម៉ែត្រ ខាងជើងផ្លូវដែលលោកត្រូវគេបញ្ចុះនោះ។ ខ្ញុំយល់ថា មានមូលហេតុដូចខាងក្រោមនេះ។ លោកអ័ប្រាហាំបានទិញដីមួយកន្លែងនៅម៉ាក់ពេឡា យ៉ាកុបគាត់ចង់អោយគេបញ្ចុះសពលោកទីនោះ ជាមួយនឹងពួកព្ធយុកោរបស់លោក។ លោកហើយនិងពួកព្ធយុកោមានសេចក្តីសង្ឃឹមលើការរស់ឡើងវិញជាមួយគ្នាទាំងអស់នៅទីនោះ។

## យ៉ូសែបរំខាប់ការភ័យខ្លាចរបស់ពួកបងប្អូន

**រួចក្រោយដែលបានបញ្ចុះសពឪពុកហើយ នោះយ៉ូសែបត្រឡប់ទៅឯស្រុកអេស៊ីព្ទវិញ ព្រមទាំងពួកបងប្អូន នឹងអស់អ្នកដែលបានឡើងទៅជាមួយ ដើម្បីនឹងបញ្ចុះសពឪពុកគាត់ផង កាលពួក**

**បងរបស់យ៉ូសែបឃើញថា ឪពុកបានស្លាប់ហើយ នោះគេជំនុំគ្នាថា ប្រហែលជាយ៉ូសែបនឹងស្អប់យើងហើយ មុខជាវានឹងសងសឹកចំពោះយើងជាមិនខាន ដោយព្រោះគ្រប់ទាំងការអាក្រក់ដែលយើងបានធ្វើដល់វារួចគេចាត់ម្នាក់ ឱ្យទៅនិយាយនឹងយ៉ូសែបថា ឪពុកប្អូនបានផ្តាំទុកមុនដែលគាត់ស្លាប់ថា ចូរឯងរាល់គ្នានិយាយនឹងយ៉ូសែបដូច្នេះថា សូមអត់ទោសសេចក្តី រំលងនឹងអំពើបាបរបស់ពួកបងឥឡូវ ដ្បិតគេបានប្រព្រឹត្តអាក្រក់នឹងប្អូនទៅហើយ ដូច្នេះសូមអត់ទោសពួកអ្នកបំរើរបស់ព្រះនៃឪពុកប្អូនឥឡូវ កាលយ៉ូសែបបានឮសេចក្តីដែលគេនិយាយនោះក៏យំ (លោកុ.៥០:១៤-១៧)។**

ពួកបងប្អូនប្រុសៗរបស់យ៉ូសែបជំរាបយ៉ាកុបថា បន្ទាប់ពីលោកស្លាប់ទៅ ពួកបងប្រុសទាំងនោះ ខ្លាចណាស់ ក្រែងលោយ៉ូសែបសងសឹកដោយប្រការណាមួយ។ យ៉ាកុបបានផ្តាំផ្ញើរដល់យ៉ូសែប មិនអោយសងសឹកដល់បងប្អូនរបស់ខ្លួនទេ។ នៅពេលដែលពួកបងៗទាំងនោះ បានសារភាពនៅចំពោះយ៉ូសែប យ៉ូសែបបានយំជាខ្លាំង។

**ហើយពួកបងគាត់ ក៏ទៅទំលាក់ខ្លួនក្រាបចុះនៅចំពោះមុខគាត់ដែរដោយពាក្យថា មើលយើងខ្ញុំជាអ្នកបំរើប្អូន (លោកុ.៥០:១៨)។**

ត្រង់នេះយើងឃើញថា យល់សប្តិរបស់យ៉ូសែបនោះ បានសម្រេចរឹងរឹតតែច្បាស់ឡើងជាបន្តបន្ទាប់។

**នោះយ៉ូសែបឆ្លើយតបថា កុំឲ្យខ្លាចឡើយ ដ្បិតតើខ្ញុំជាព្រះឬអី (លោកុ.៥០:១៩)។**

យ៉ូសែបមានទម្លាប់ថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ក្នុងគ្រប់ហេតុការណ៍ទាំងអស់ ដែលលោកឆ្លងកាត់។ ខគម្ពីរខាងក្រោមនេះ ជាខគម្ពីរដែលយើងត្រូវយកចិត្តទុកដាក់អោយបានខ្លាំងជាទីបំផុត។

**អ្នករាល់គ្នាបានគិតធ្វើអាក្រក់ដល់ខ្ញុំ តែព្រះទ្រង់សំរេចជាការល្អវិញ ដើម្បីនឹងសង្គ្រោះដល់ជីវិតនៃមនុស្សជាច្រើន ដូចជាបានកើតមានសព្វថ្ងៃនេះ (លោកុ.៥០:២០)។ (សូមអានព្រមគ្នា)**

មិត្តសម្លាញ់ បងប្អូនប្រុសស្រីអើយ ព្រះជាម្ចាស់មានផែនការវែងឆ្ងាយសម្រាប់ជីវិតរបស់យើង ជាងយើងអាចមើលឃើញ។ ខ្ញុំផ្ទាល់ សូមសារភាពដូច្នេះថា ខ្ញុំមើលមិនបានឆ្ងាយហួសពីចុងច្រមុះរបស់ខ្ញុំទេ ពេលណាខ្ញុំជួបជាមួយនឹងទុក្ខលំបាក។ នៅពេលជួបជាមួយទុក្ខលំបាក ខ្ញុំតែងតែសួរខ្លួនឯងយ៉ាងដូច្នេះថា "ហេតុអ្វីបានជាព្រះអនុញ្ញាតអោយការនេះ កើតឡើងចំពោះតែខ្ញុំម្នាក់ឯងប៉ុណ្ណោះ?" យើងគ្រប់គ្នាត្រូវ

រំឮកខ្លួនឯងម្តងហើយម្តងទៀតថា ព្រះជាម្ចាស់មានបំណងល្អបណ្តាច់សម្រាប់ជីវិតយើងទាំងអស់គ្នា។ ព្រះជាម្ចាស់មិនដែលអនុញ្ញាតអោយអ្វីមួយកើតឡើងមកដល់ជីវិតយើង បើព្រះអង្គមិនចង់អោយមានបំណងល្អណាមួយកើតឡើងដល់ជីវិតយើងនោះទេ។ សូមលោកអ្នក មេត្តាស្តាប់សេចក្តីឆ្លើយតបរបស់យ៉ូសែប ចំពោះការភ័យខ្លាចរបស់បងប្អូនចុះ!

> **ដូច្នេះកុំឱ្យខ្លាចឡើយ ខ្ញុំនឹងចិញ្ចឹមអ្នករាល់គ្នា ហើយនឹងកូនចៅរបស់អ្នករាល់គ្នាដែរ គាត់ក៏កំសាន្តចិត្តគេ ហើយនិយាយស្រទន់នឹងគេ ឯយ៉ូសែបនឹងពួកគ្រួឪពុកគាត់ទាំងប៉ុន្មាន ក៏នៅក្នុងស្រុកអេស៊ីព្ទតទៅ យ៉ូសែបគាត់រស់នៅបានអាយុ១១០ឆ្នាំ គាត់ឃើញកូនចៅរបស់អេប្រាអិមដល់៣ដំណ ឯកូនចៅម៉ាគារ ជាកូនម៉ាន៉ាសេ នោះគាត់ក៏បានកាន់ដាក់នៅលើភ្លៅដែរ (លោកុ.៥០: ២១-២៣)។**

ខគម្ពីរខាងលើសម្តែងថា យ៉ូសែបមានជីវិតរស់នៅរហូតដល់បានឃើញចៅទួតរបស់លោក។

## មរណភាព និងពិធីបញ្ចុះសពរបស់យ៉ូសែបនៅអេស៊ីព្ទ

**រួចគាត់និយាយទៅបងប្អូនថា ខ្ញុំហៀបនឹងស្លាប់ហើយ តែព្រះទ្រង់នឹងប្រោសអ្នករាល់គ្នាជាមិនខាន ហើយនឹងនាំអ្នករាល់គ្នាឡើង ចេញពីស្រុកអេស៊ីព្ទនេះ ទៅក្នុងស្រុកដែលទ្រង់បានស្បថថានឹងឲ្យដល់អ័ប្រាហាំ អ៊ីសាក នឹងយ៉ាកុប យ៉ូសែបក៏ឲ្យពួកកូនចៅអ៊ីស្រាអែលស្បថដោយផ្តាំថា ព្រះទ្រង់នឹងប្រោសអ្នករាល់គ្នាជាមិនខាន នោះអ្នករាល់គ្នាត្រូវយកឆ្អឹងខ្ញុំចេញពីនេះ ឡើងទៅជាមួយផង យ៉ូសែបគាត់ក៏ស្លាប់ទៅអាយុគាត់បាន១១០ឆ្នាំ ហើយគេដាក់បារទសពគាត់ រួចដាក់ចុះក្នុងមឈូសនៅស្រុកអេស៊ីព្ទ (លោកុ.៥០:២៤-២៦)។**

ហេតុអ្វីបានជាគេមិនយកសពយ៉ូសែបមកបញ្ចុះនៅទឹកដីកាណាន? ខ្ញុំយល់ថា អ្នកស្រុកនៅប្រទេសអេស៊ីព្ទ បានលើកយកយ៉ូសែបធ្វើជាបុព្វបុរសមួយរូប ហើយក្នុងនាមលោកជាបុព្វបុរសរបស់ប្រទេសអេស៊ីព្ទ មនុស្សគ្មានសិទ្ធិយកសពលោកមកបញ្ចុះនៅទឹកដីណាផ្សេងទៀត ខុសអំពីទឹកដីអេស៊ីព្ទនោះទេ។ ខ្ញុំជឿពិតប្រាកដថា ផ្នូររបស់យ៉ូសែបជាផ្នូរដែលជាវិមានធំមួយនៅក្នុងប្រទេសអេស៊ីព្ទ។

ប៉ុន្តែយ៉ូសែបបានផ្តាំផ្ញើរជាមួយនឹងពួកកូនចៅរបស់លោកថា "នឹងមានពេលដែលព្រះទ្រង់នឹងប្រោសដល់អ្នករាល់គ្នាជាមិនខាន នោះអ្នករាល់គ្នាត្រូវយកឆ្អឹងខ្ញុំចេញពីទីនេះ ឡើងទៅជាមួយផង"។ យ៉ូសែបមានសេចក្តីសង្ឃឹមដដែល ដូចលោកយ៉ាកុបមានដែរ ពោលគឺមានទំនុកចិត្តថា ព្រះជាម្ចាស់ទ្រង់ប្រទានទឹកដីកាណានជាកេរ្តិ៍អាករដ៏អស់កល្បជានិច្ចតទៅ។ យ៉ូសែបជឿថា ព្រះជាម្ចាស់នឹងធ្វើអោយលោករស់ឡើងវិញ ដើម្បីទទួលកេរ្តិ៍មរតកនៅក្នុងទឹកដីសន្យាជាមួយនឹងពួកឰយុកោលោកដែរ។

ព្រះគម្ពីរហេព្រើររៀបរាប់អំពីជំនឿរបស់យ៉ូសែបថា "ដោយសារសេចក្តីជំនឿនោះ យ៉ូសែបបានប្រាប់ពីដំណើរពួកជនជាតិអ៊ីស្រាអែល ដើរចេញពីស្រុកអេស៊ីព្ទ ក៏ផ្តាំពីដំណើរសពរបស់ខ្លួន ក្នុងកាលដែលហៀបនឹងផុតដង្ហើមទៅផង" (ហេព្រើរ១១:២២)។ នៅក្នុងព្រះគម្ពីរនិក្ខមនំជំពូក១៣ យើងឃើញហេតុការណ៍ដែលព្រះជាម្ចាស់ធ្វើអោយសំណូមពររបស់យ៉ូសែបបានសម្រេចមែន។ លោកម៉ូសេរួមទាំងពួកកូនចៅអ៊ីស្រាអែលទាំងអស់គ្នាស្ពាយធាតុយ៉ូសែបមកជាមួយ ពេលដែលគេចាកចេញពីប្រទេសអេស៊ីព្ទ។

កំណត់គម្ពីរលោកុប្បត្តិ ឈានមកដល់ទីបញ្ចប់ហើយ។ គម្ពីរនេះចាប់ផ្តើមពីព្រះបង្កើតផ្ទៃមេឃនិងផែនដី រួចហើយបញ្ចប់ជាមួយនឹងក្តារមឈូសនៅក្នុងប្រទេសអេស៊ីព្ទ។ តើគ្រួសាររបស់មនុស្សលោក នឹងក្លាយទៅជាយ៉ាងណា? អំពើបាបបានជ្រៀតចូលមកក្នុងនាបនកម្មរបស់ព្រះជាម្ចាស់។ នាបនកម្ម គឺអ្វីៗសព្វសារពើដែលព្រះជាម្ចាស់បង្កើតឡើងមក។